ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦.១៣..០១៨...០១៣.(ប.ភ.៣-ម

ថ្ងៃពុធ ៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំឆ្នាំ២០១៨

នៅថ្ងៃអង្គារ ៨រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិដែលដឹកនាំដោយ លោក Jarkko Turunen បានចូលជួបរាយការណ៍ជូនពីការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនៅឆ្នាំ២០១៨ និងទស្សនវិស័យក្នុងរយៈពេលមធ្យម។

ក្រុមបេសកកម្មបានអបអរសាទររាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបានវឌ្ឍនភាពសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈការទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់រឹងមាំ និងកំណែទម្រង់សំខាន់ៗ នារយៈពេលកន្លងមក។ កំណើនប្រាក់ចំណូលបានកើនឡើងលឿនជាងប្រទេសមួយចំនួនក្នុងតំបន់ ភាពក្រីក្របានធ្លាក់ចុះ ហើយសេដ្ឋកិច្ចបានចាប់ផ្តើមធ្វើពិពិធកម្មជាបន្តបន្ទាប់។

កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ ត្រូវបានព្យាករថានឹងសម្រេចបានក្នុងអត្រា ៧,៣% ដែលគាំទ្រជាចម្បងដោយតម្រូវការខាងក្រៅនិងគោលនយោបាយសារពើពន្ធវិត្ថារកម្ម ខណៈដែលអតិផរណាបន្តមានកម្រិតទាបក្នុងរង្វង់ ២,៥%។ ទុនបម្រុងអន្តរជាតិត្រូវបានរំពឹងថាបន្តកើនឡើងដល់ ៩,៦ ប៊ីលានដុល្លារអាមេរិកនៅចុងឆ្នាំ២០១៨ ដែលធានាការទូទាត់ការនាំចូលនាឆ្នាំបន្ទាប់បានប្រមាណ ៥ខែ។ វិស័យធនាគារមានវឌ្ឍនភាពល្អប្រសើរ ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសុខភាពល្អ ហើយបានបន្តសេវាហិរញ្ញវត្ថុដោយប្រសិទ្ធភាព ដែលបានពង្រីកបរិយាប័ន្នហិរញ្ញវត្ថុជាលំដាប់។ កំណើនឥណទានរបស់គ្រឹះស្ថានធនាគារត្រូវបានរំពឹងថាកើនឡើងប្រមាណ ១៩% ហើយឥណទានដែលផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុកើនឡើងក្នុងអត្រា ៣៥%។

នៅឆ្នាំ២០១៩និងរយៈពេលមធ្យម កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងរក្សាក្នុងរង្វង់ ៧% ជាមួយនឹងអត្រាអតិផរណាក្នុងរង្វង់ ៣% ក្នុងរយៈកាលមធ្យម។ ក្រុមបេសកកម្មក៏បានផ្តល់អនុសាសន៍ដល់កម្ពុជាឱ្យបន្តធ្វើកំណែទម្រង់ចម្បងៗ និងបន្តពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងហានិភ័យដែលអាចកើតឡើងជាយថាហេតុដល់កំណើនសេដ្ឋកិច្ច។

ឯកឧត្តមទេសាភិបាល បានថ្លែងអំណរគុណដល់បេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលដឹកនាំដោយ លោក Jarkko Turunen ដែលបានមកបំពេញបេសកកម្មមាត្រា IV ប្រកបដោយ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជោគជ័យ។ ធនាគារជាតិនៃកម្ពុជាវាយតម្លៃខ្ពស់ចំពោះលទ្ធផលវាយតម្លៃសេដ្ឋកិច្ចនិងអនុសាសន៍របស់ IMF ដែលនឹងរួមចំណែកផ្តល់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។ ឯកឧត្តមទេសាភិបាលក៏បានថ្លែងអំណរគុណចំពោះការរួមចំណែករបស់ IMF ក្នុងការជួយតាមដានស្ថានភាពសេដ្ឋកិច្ច ផ្តល់ជំនួយបច្ចេកទេស និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា និងបានសុំឱ្យ IMF បន្តជួយផ្តល់នូវជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាលថែមទៀតនាពេលខាងមុខ។

ទំនាក់ទំនង៖
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh